**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ និងអបអរសាទរ

## ឯកឧត្តមកិត្តិបរិក្សបណ្ឌិត ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវការចូលរួមអបអរសាទរក្នុងឱកាសដែល **ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី** ត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** បានចេញព្រះរាជក្រឹត្យផ្តល់គោរមងារ កិត្តិយសនៃរាជបណ្ឌិត្យសភាកម្ពុជា ជា «**កិត្តិបរិក្សបណ្ឌិត**» កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។

យើងខ្ញុំសូមគោរពជូនពរ និងអបអរសាទរ **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត ហោ ណាំហុង** សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន ប្រាជ្ញាឈ្លាសវៃភ្លឺថ្លា ជន្មាយុយឺនយូរ ឈ្នះអស់សត្រូវគ្រប់ទិសទី និងទទួលបានជោគជ័យថ្មីថែមទៀតក្នុងបុព្វហេតុជាតិ មាតុភូមិ ប្រជាជន ប្រកបដោយការអភិវឌ្ឍ និងរីកចម្រើនជានិច្ចនិរន្តរ៍តរៀងទៅ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ យើងខ្ញុំសូមគោរពបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយប្រោះព្រំប្រសិទ្ធពរជ័យជូន **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត ហោ ណាំហុង និងលោកជំទាវ ព្រមទាំង បុត្រា បុត្រី និងចៅៗ** ជាទីស្រឡាញ់ជួបប្រទះតែសេចក្តីសុខ សុភមង្គល និងប្រកបដោយពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមបរិក្សបណ្ឌិត ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅពីយើងខ្ញុំ៕

ថ្ងៃ សុក្រ ១១ កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh